

# បរិយាបន្ន និងគុណភាព

នៅតាម

សាលារៀន
ឥស្លាម

សាលា
ពុទ្ធិកសិក្សា

សាលារៀន
បណ្តែតទឹកនៅកម្ពុជា

អង្គការយូនីសេហ្វ ប្រចាំនៅកម្ពុជា
ខែ មិថុនា-កញ្ញា ឆ្នាំ ២០១៨

# ខ្លឹមសារសង្ខេប

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងផ្ដល់ការយល់ដឹងកាន់តែប្រសើរស្ដីពីសហគមន៍សាលារៀនចំនួន ៣ នៅកម្ពុជា (សាលារៀនឥស្លាម សាលាពុទ្ធិកសិក្សា និងសាលារៀនបណ្ដែតទឹក) ដោយផ្ដោតសំខាន់លើការកំណត់រកបញ្ហាប្រឈមក្នុងការផ្ដល់ការអប់រំបរិយាបន្នប្រកបដោយគុណភាព។

កន្លងមក ប្រព័ន្ធអប់រំនៅកម្ពុជា សម្រេចបានវឌ្ឍនភាពយ៉ាងច្រើន។ ចំនួនសិស្សចុះឈ្មោះចូលរៀនក្នុងប្រព័ន្ធសាលារដ្ឋបានកើនឡើងយ៉ាងលឿននៅគ្រប់ភូមិសិក្សា។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការចុះឈ្មោះចូលរៀនថ្នាក់បឋមសិក្សា ស្ទើរតែសម្រេចបាននូវយុគភាពយេនឌ័រ។ ភាពល្អប្រសើរទាំងនេះកើតចេញពីការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្ដល់លទ្ធភាពទទួលបានការអប់រំប្រកបដោយសមធម៌។ សមិទ្ធផលនេះត្រូវបានឆ្លុះបញ្ចាំង ក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំទី ១ និងត្រូវបានគូសបញ្ជាក់ជាបន្តបន្ទាប់តាមរយៈការអនុវត្តគោលនយោបាយដែលធានានូវលទ្ធភាពទទួលបានការអប់រំប្រកបដោយសមធម៌ ការសិក្សាប្រកបដោយគុណភាព និងប្រសិទ្ធភាពនៃការដឹកនាំតាមសាលារៀនដូចជា ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨។ ការប្ដេជ្ញាចិត្តនេះនឹងនៅតែបន្តរំលេចក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៩-២០២៣ ដែលកំពុងត្រូវបានតាក់តែងឡើង។

ថ្វីបើមានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ មិនមែនកុមារកម្ពុជាគ្រប់រូបសុទ្ធតែអាចទទួលបានការរៀនសូត្រប្រកបដោយគុណភាពនោះទេជាពិសេសកុមារមកពីសហគមន៍ជួបការលំបាក និងងាយរងគ្រោះ។ គួរកត់សម្គាល់ថាកម្ពុជាមានក្រុមជនជាតិភាគតិចជាច្រើនដែលកំពុងជួបការលំបាក ប៉ុន្តែកង្វះពេលវេលានិងធនធានមនុស្សបូករួមនឹងឧបសគ្គផ្នែកភស្តុភារ ការស្រាវជ្រាវនេះសិក្សាតែសហគមន៍សាលារៀនទាំងបីនេះ (សាលារៀនឥស្លាម សាលាពុទ្ធិកសិក្សា និងសាលារៀនបណ្ដែតទឹក)។

បច្ចុប្បន្ន សហគមន៍ទាំងនេះទទួលបានអត្ថប្រយោជន៍តិចតួចពីការងារវិស័យអប់រំ ក្នុងប្រទេសរបស់អង្គការយូនីសេហ្វ។ ដូច្នេះ ការស្រាវជ្រាវនេះមានគោលបំណងកំណត់រកវិធីដែលអង្គការយូនីសេហ្វ និងដៃគូផ្សេងទៀត អាចផ្ដល់ជំនួយកាន់តែផ្ទាល់ដល់កុមារកំពុងសិក្សានៅសាលាទាំងបីប្រភេទ តាមរយៈការផ្ដល់សេវាអប់រំឱ្យរឹតតែប្រសើរ។

## គោលដៅ និងគោលបំណង

ការស្រាវជ្រាវនេះមិនមានគោលដៅធ្វើការវាយតម្លៃគ្រប់ជ្រុងជ្រោយពីសហគមន៍សាលារៀនទាំងនេះទេ ប៉ុន្តែផ្ដោតលើការស្វែងយល់ពីកាលៈទេសៈទូទៅនិងមានគោលបំណង៖

១) ផ្ដល់ការយល់ដឹងពីបញ្ហាប្រឈមរបស់សហគមន៍សាលារៀនឥស្លាម សាលាពុទ្ធិកសិក្សា និងសាលារៀនបណ្ដែតទឹកនិង

២) កំណត់រកវិធីបង្កើនការអប់រំបរិយាបន្នប្រកបដោយគុណភាពក្នុងសាលារៀនទាំងនេះ។

ដើម្បីសម្រេចបានគោលបំណងខាងលើ ការស្រាវជ្រាវផ្ដោតលើចំណុចសំខាន់ ៣ ៖ (១) បញ្ហាប្រឈមជាក់លាក់របស់សហគមន៍សាលារៀនទាំងនេះ ក្នុងការផ្ដល់ការអប់រំបរិយាបន្នប្រកបដោយគុណភាព (២) បទប្បញ្ញត្តិប្រព័ន្ធរដ្ឋាភិបាល ឬគោលការណ៍ណែនាំស្ដីពីការផ្ដល់សេវាអប់រំដល់សហគមន៍សាលារៀនទាំងនេះ និង (៣) ចំណុចចាប់ផ្ដើមសម្រាប់ឲ្យអង្គការយូនីសេហ្វ និងដៃគូអភិវឌ្ឍន៍ផ្សេងទៀតលើកកម្ពស់ការអប់រំបរិយាបន្ន ប្រកបដោយគុណភាពនៅតាមសាលារៀនទាំងនេះ។

# វិធីសាស្រ្ត

គុណភាព បរិយាបន្ន និងភាពងាយរងគ្រោះគឺជាចំណុចស្នូលទាំង ៣ សម្រាប់ការវិភាគក្នុងការស្រាវជ្រាវនេះ និងមានការរៀបចំកិច្ចការជាបីដំណាក់កាល ៖ ការពិនិត្យឡើងវិញលើឯកសារមានស្រាប់ ការប្រមូល និងវិភាគទិន្នន័យ និងការព្រាងរបាយការណ៍។ ការពិនិត្យឡើងវិញលើឯកសារមានស្រាប់ រួមមានការពិនិត្យឡើងវិញលើអត្ថបទទិន្នានុប្បវត្តិស្រាវជ្រាវ សារព័ត៌មាន ឯកសារពីអ្នកកាសែត ឯកសារ និងរបាយការណ៍របស់ក្រសួង និងអង្គការសង្គមស៊ីវិលនានាដែលធ្វើការងារពាក់ព័ន្ធនឹងសាលារៀនឥស្លាម សិស្សចាមមូស្លីម សាលាពុទ្ធិកសិក្សា និងសាលារៀនបណ្តែតទឹក។

ក្នុងការប្រមូលទិន្នន័យ អ្នកស្រាវជ្រាវបានចុះទៅកាន់សាលារៀនតាមមូលដ្ឋាន សម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ៗ និងរៀបចំកិច្ចពិភាក្សាក្រុមគោលដៅ ក្នុងខេត្តកំពង់ចាម បាត់ដំបង និងពោធិ៍សាត់។ ជារួម ក្រុមរបស់យើងបានចុះទៅកាន់សាលារៀន ១២ (សាលារៀនបណ្តែតទឹក ៣ សាលារៀនពុទ្ធិកសិក្សា ៥ សាលារៀនឥស្លាម ៣ និងសាលារដ្ឋសម្បូរសិស្សជនជាតិចាម ១) និងបានធ្វើបទសម្ភាសន៍ និងកិច្ចពិភាក្សាក្រុមគោលដៅ ២៣។ អ្នកផ្តល់បទសម្ភាសន៍រួមមាន មន្ត្រីក្រសួង អង្គការមិនមែនរដ្ឋាភិបាលមូលដ្ឋាន អង្គការដៃគូ បុគ្គលិកអង្គការសហប្រជាជាតិ អ្នកស្រាវជ្រាវ នាយកសាលា គ្រូបង្រៀន និងសិស្សានុសិស្ស។

# លទ្ធផលរកឃើញសំខាន់ៗ

## ១. ឧបសគ្គចម្បងគឺការជ្រើសរើស និងបណ្តុះបណ្តាលគ្រូបង្រៀន

បញ្ហាពាក់ព័ន្ធនឹងការជ្រើសរើស និងបណ្តុះបណ្តាលគ្រូបង្រៀនសុទ្ធតែកើតមានក្នុងសហគមន៍សាលារៀនទាំងបី។ ខណៈដែលសហគមន៍សាលារៀនទាំងនេះកំពុងជួបការលំបាក និង/ឬងាយរងគ្រោះ និងជាញឹកញាប់មានបញ្ហាហិរញ្ញវត្ថុ មិនសូវមានគ្រូចង់បង្រៀននៅសាលារៀនទាំងនេះឡើយ ហើយវាបានធ្វើឲ្យមានកង្វះគ្រូដែលមានសមត្ថភាព។ ក្រៅពីនេះ ការស្រាវជ្រាវបង្ហាញថា មិនសូវមានការបណ្តុះបណ្តាល និងវិក្រឹត្យការវិជ្ជាជីវៈសម្រាប់គ្រូបង្រៀនភាគច្រើននៅតាមសាលារៀនទាំងនេះនោះទេ។ នៅពេលគ្មានការបណ្តុះបណ្តាលវិក្រឹត្យការវិជ្ជាជីវៈគ្រូបង្រៀនមិនអាចទទួលបានចំណេះដឹង និងការអនុវត្តថ្មីៗក្នុងការបង្រៀនរបស់ខ្លួន ហើយជារួម វាបានជះផលអវិជ្ជមានលើគុណភាពនៃការបង្រៀន។

## ២. គណៈគ្រប់គ្រងសាលារៀនពុំមានសមត្ថភាពគ្រប់គ្រាន់

នៅតាមសាលារៀនជាច្រើនក្នុងសំណាកគំរូនេះ គណៈគ្រប់គ្រងសាលារៀនជាច្រើនគ្មាន ឬមានបទពិសោធន៍ការងារតិចតួច។ ទន្ទឹមនឹងនេះ គ្មានវគ្គបណ្តុះបណ្តាលគ្រប់គ្រាន់សម្រាប់នាយកសាលា និងអ្នកគ្រប់គ្រងសាលារៀនឡើយ។ នាយកសាលាជាច្រើនលើកឡើងថា ពួកគាត់មិនសូវមានជំនាញ និងធនធានចាំបាច់ដើម្បីគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាពឡើយ។ ជំនាញចាំបាច់ទាំងនោះរួមមាន ការរៀបចំថវិកា ការធ្វើផែនការ ការគ្រប់គ្រងបុគ្គលិក ការធ្វើរបាយការណ៍ និងការធ្វើលទ្ធកម្ម និងសមត្ថភាពតម្រែតម្រង់ទស្សនៈវិស័យសាលារៀន និងបណ្តុះទំនាក់ទំនងប្រកបដោយអត្ថន័យជាមួយបុគ្គលិក មាតាបិតា សិស្ស និងសហគមន៍ទាំងមូល។

## ៣. សាលារៀនពុំមានធនធានគ្រប់គ្រាន់ដែលធ្វើឲ្យប៉ះពាល់ដល់គុណភាពជារួម

សាលារៀនភាគច្រើនក្នុងការសិក្សាស្រាវជ្រាវនេះមិនសូវមានធនធាន ដើម្បីផ្តល់ការអប់រំប្រកបដោយគុណភាពឡើយ (កង្វះសម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធ)។ ធនធានមានស្រាប់ ដូចជា សម្ភារសិក្សា សៀវភៅគ្រូ និងសម្ភារផ្ទៃទាំ និងជួសជុលអគារសិក្សា សុទ្ធតែចាស់ៗ និងមានតិចតួច និងមិនគ្រប់គ្រាន់ ចំណែកថវិកាសាលារៀនសម្រាប់បើក

ជូនបុគ្គលិក ជួយដល់គម្រោង និងទិញសម្ភារចាំបាច់នានាពេញមួយឆ្នាំសិក្សា ក៏ខ្វះខាតផងដែរ។ បញ្ហាទាំងនេះបានរាំងស្ទះដល់ផ្តល់ការអប់រំប្រកបដោយគុណភាពនៅតាមសាលារៀនទាំងនេះ ប៉ុន្តែបុគ្គលិកសាលារៀន និងមាតាបិតានៅតែប្តេជ្ញាចិត្តផ្តល់ការអប់រំប្រកបដោយគុណភាព។

## ៤. សហគមន៍សាលារៀនប្រឈមនឹងភាពងាយរងគ្រោះចម្រុះ

**សហគមន៍ងាយរងគ្រោះ ៖** ភាពងាយរងគ្រោះគឺជាចំណុចវិភាគដ៏សំខាន់មួយក្នុងការស្រាវជ្រាវនេះ។ តាមធម្មតា កុមារត្រូវបានសន្មតថាងាយរងគ្រោះ ដោយមិនគិតពីស្ថានភាពសង្គមរបស់ពួកគេ។ ប៉ុន្តែមានកុមារដែលស្ថិតក្នុងស្ថានភាពសង្គម នយោបាយ និងបរិស្ថានមួយចំនួនដែលធ្វើឲ្យពួកគេងាយរងគ្រោះជាងកុមារផ្សេងទៀត។ សិស្សនៅតាមសហគមន៍សាលារៀនទាំងបីនេះជាកុមារដែលងាយរងគ្រោះបំផុតនៅកម្ពុជា ដោយសារតែជាតិពន្ធ ស្ថានភាពសេដ្ឋកិច្ច និងទីតាំងដាច់ស្រយាលរបស់ពួកគេ។

**ការអប់រំបរិយាបន្ន ៖** គោលនយោបាយបច្ចុប្បន្នមិនទាន់បំពេញតម្រូវការគុណតម្លៃសាសនា សមត្ថភាពភាសា ស្ថានភាពសេដ្ឋកិច្ចសង្គម និង/ឬភូមិសាស្ត្ររបស់សិស្សឲ្យបានគ្រប់គ្រាន់ឡើយ។ ប្រព័ន្ធសាលារៀនទាំងបីនេះជាឧទាហរណ៍នៃការអប់រំជាជម្រើស ដែលអាចផ្តល់លទ្ធភាពទទួលបានការអប់រំបរិយាបន្នកាន់តែប្រសើរដល់សហគមន៍ចម្រុះ។ ខណៈដែលសាលាទាំងនេះអាចមានលក្ខណៈបរិយាបន្នលើផ្នែកខ្លះ ប្រភេទសាលារៀននីមួយៗនឹងអាចទាញប្រយោជន៍ពីការអប់រំបរិយាបន្ន ដូចជា ការផ្តល់ការអប់រំពហុភាសា ការធានាលទ្ធភាពរបស់សិស្សពិការក្នុងការទទួលបានការអប់រំ ការផ្តល់សម្ភារសិក្សាកាន់តែប្រសើរដល់សិស្សដែលមានពិការភាព ផ្នែកការអភិវឌ្ឍ ការត្រៀមខ្លួន និងបណ្តុះបណ្តាលគ្រូបង្រៀនស្តីពីគរុកោសល្យបែបបរិយាបន្ន ការរួមបញ្ចូលសហគមន៍ក្នុងយុទ្ធនាការរួមបញ្ចូល ការលើកកម្ពស់សមធម៌យេនឌ័រ ការគាំទ្រកាន់តែប្រសើរដល់កុមារដែលត្រូវធ្វើការដើម្បីជួយដល់គ្រួសារ និងការពង្រឹងការប្រមូលទិន្នន័យ និងការពិនិត្យតាមដាន។

# អនុសាសន៍

## សាលារៀនឥស្លាម

### អនុសាសន៍រយៈពេលខ្លី

#### ១. ការបង្កើនលទ្ធភាពទទួលបានការបណ្តុះបណ្តាល និងវិក្រឹត្យការ

ក្រសួងអប់រំ យុវជន និងកីឡា (អយក) បានដាក់ពង្រាយគ្រូបង្រៀន ១៥០០ នាក់នៅតាមសាលារៀនឥស្លាម។ ដូច្នេះ ក្រសួងគួរផ្តល់ការបណ្តុះបណ្តាលវិក្រឹត្យការគរុកោសល្យដល់គ្រូបង្រៀនទាំងនេះដូចគ្រូសាលារដ្ឋដែរ។ ចំណុច ដែលត្រូវបានលើកឡើងជាអនុសាសន៍ គឺក្រសួង អយក គួរពង្រីកការបណ្តុះ បណ្តាលរយៈពេល ១ ឆ្នាំដូចគ្នាដល់គ្រូបង្រៀននៅសាលារៀនឥស្លាមដែលក្លាយជាគ្រូរដ្ឋ។ ខណៈដែលប្រធានបទ និងខ្លឹមសារក្នុងការបណ្តុះបណ្តាលអាចខុសពីសាលារដ្ឋ ប៉ុន្តែគរុកោសល្យចាំបាច់សម្រាប់ផ្តល់ការអប់រំដែលមានគុណភាព គឺដូចគ្នា។

### អនុសាសន៍រយៈពេលវែង

#### ១. ការបង្កើនការពិនិត្យតាមដានហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងអនាម័យ

គួរមានការពិនិត្យតាមដានជាប្រព័ន្ធលើហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងអនាម័យនៅតាមសាលារៀនឥស្លាម។ សាលារៀនពីរក្នុងចំណោមសាលារៀនទាំងបីដែលក្រុមស្រាវជ្រាវបានចុះទៅមានធនធានគ្រប់គ្រាន់ និងមានហេដ្ឋា

រចនាសម្ព័ន្ធទឹកស្អាត និងអនាម័យសមស្រប ប៉ុន្តែសាលារៀនឥស្លាមមួយទៀតគ្មានហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងអនាម័យឡើយ។

### ២. បង្កើនសមត្ថភាពគ្រប់គ្រងទិន្នន័យកម្រិតសាលារៀន

ក្រុមស្រាវជ្រាវមានការលំបាកក្នុងការទទួលបានស្ថិតិស្តីពីសាលារៀនឥស្លាម ក្រៅពីស្ថិតិជនជាតិភាគតិច ដែលបែងចែកតាមប្រភេទ ដូចជា ព័ត៌មានស្តីពីចំនួនសិស្សក្នុងសហគមន៍ជនជាតិចាម។ ដូច្នេះ ក្រុមស្រាវជ្រាវស្នើឲ្យមានការបង្កើនតម្លាភាពទិន្នន័យប្រមូលដោយ គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា។ ការចែករំលែកព័ត៌មានស្តីពីចំនួនសិស្សចុះឈ្មោះចូលរៀន ចំនួនគ្រូអត្រាបញ្ចប់ការសិក្សា និងសមាសភាគជាតិពន្ធជាមួយក្រសួង អយក នឹងជួយបង្កើនការយល់ដឹង និងជួយដល់ការតាក់តែងគោលនយោបាយនៅគ្រប់កម្រិត។

### ៣. ពង្រឹងកម្មវិធីផ្សព្វផ្សាយ និងតស៊ូមតិតាមសហគមន៍

កម្មវិធីផ្សព្វផ្សាយតាមសហគមន៍ដែលធ្វើឲ្យមាតាបិតា យល់ដឹងពីសារៈសំខាន់នៃការអប់រំដោយមិនគិតពីប្រភេទសាលារៀន ពិតជាសំខាន់ណាស់។ អាពាហ៍ពិពាហ៍កុមារត្រូវបានកំណត់ជាហេតុផលមួយនៃការបោះបង់ការសិក្សានៅសាលារៀនមួយ។ បញ្ហានេះអាចដោះស្រាយបានតាមរយៈកម្មវិធីតស៊ូមតិតាមសហគមន៍ដែលលើកឡើងពីគុណវិបត្តិនៃអាពាហ៍ពិពាហ៍កុមារ។ ជនជាតិខ្មែរមូស្លីម ចាមមូស្លីម និងសហគមន៍ជនជាតិខ្មែរឥស្លាម នឹងទទួលបានប្រយោជន៍ពីកម្មវិធីតស៊ូមតិ។

## សាលាពុទ្ធិកសិក្សា

#### អនុសាសន៍រយៈពេលខ្លី

### ១. បង្កើនការផ្តល់មូលនិធិដល់ការបោះពុម្ពសៀវភៅសាសនា កម្មវិធីសិក្សា និងសៀវភៅគ្រូ

រាជរដ្ឋាភិបាលកម្ពុជាបានចាត់តាំងឲ្យក្រសួងធម្មការ និងសាសនា រៀបចំ និងលើកកម្ពស់វិស័យពុទ្ធិកសិក្សា។ ក្រសួងធម្មការ និងសាសនា មានភារកិច្ចបែងចែកមូលនិធិក្នុងផែនការថវិកាប្រចាំឆ្នាំរបស់ខ្លួន ដើម្បីបោះពុម្ពឲ្យបានគ្រប់គ្រាន់ និងចែកចាយឯកសារសិក្សាទាំងនេះដល់សាលារៀនតាមវត្តអារាម។ ដើម្បីឆ្លើយតបនឹងបញ្ហាខ្វះខាតគ្រូបង្រៀនក្នុងសាលាពុទ្ធិកសិក្សា ដំណោះស្រាយចំពោះមុខ និងរយៈពេលខ្លីសម្រាប់ក្រសួងធម្មការ និងសាសនា គឺការកៀរគរមូលនិធិបន្ថែមសម្រាប់សាលារៀន ដើម្បីជ្រើសរើសគ្រូជាប់កិច្ចសន្យាកាន់តែច្រើនសំដៅបំពេញតម្រូវការគ្រូរដ្ឋក្នុងក្របខណ្ឌរបស់ក្រសួងផ្ទាល់។

### ២. ការផ្សព្វផ្សាយសមស្របពីសៀវភៅពុម្ពរបស់ក្រសួង អយក ដល់សាលារៀនរួមទាំងការពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សា

ក្រសួង អយក ត្រូវផ្គត់ផ្គង់សៀវភៅពុម្ព និងឯកសារកម្មវិធីសិក្សាពាក់ព័ន្ធផ្សេងទៀតដល់សាលាពុទ្ធិកសិក្សាទាំងអស់ទូទាំងប្រទេស។ ប៉ុន្តែចំណុចនេះហាក់មិនស្តែងឡើងនៅតាមសាលារៀន ក្នុងសំណាកគំរូនេះឡើយ។ ដូច្នេះ ក្រសួង អយក គួរចាត់វិធានការដោះស្រាយបញ្ហានេះ ព្រោះគ្រប់សាលាដែលក្រុមស្រាវជ្រាវចុះទៅដល់សុទ្ធតែលើកឡើងពីបញ្ហានេះ។ សាលាពុទ្ធិកសិក្សានឹងទទួលបានប្រយោជន៍យ៉ាងច្រើនពីការពិនិត្យតាមដាន និងវាយតម្លៃជាបន្តបន្ទាប់ និងការផ្តល់ជំនួយបច្ចេកទេសដល់ ការអនុវត្តកម្មវិធីសិក្សារបស់ក្រសួង អយក។

### ៣. បង្កើនគុណភាពបណ្ណាល័យសាលារៀន

ផ្អែកតាមលទ្ធផលរួមពីការសម្ភាសន៍ក្នុងសាលាពុទ្ធិកសិក្សា ៤ និងសាកលវិទ្យាល័យមួយ សកម្មភាពអាទិភាព ៣ ដែលពាក់ព័ន្ធនឹងបណ្ណាល័យសាលារៀនដែលគណៈគ្រប់គ្រងសាលារៀនចង់កែលម្អ រួមមាន ៖ ១) ការបង្កើនបរិមាណ និងលក្ខណៈចម្រុះរបស់សៀវភៅ និងឯកសារអំណាន ពិសេសពាក់ព័ន្ធនឹងកម្មវិធីសិក្សារបស់ក្រសួង អយក ២) ការផ្តល់សៀវភៅ និងឯកសារសមស្របតាមអាយុ និងថ្មីៗ និង ៣) ការបណ្តុះបណ្តាលបណ្ណារក្ស។

## អនុសាសន៍រយៈពេលវែង

### ១. ផ្តល់ការបណ្តុះបណ្តាលគ្រប់គ្រាន់ដល់គ្រូជាប់កិច្ចសន្យា និងគ្រូសហគមន៍/ស្ម័គ្រចិត្ត

ក្រសួងធម្មការ និងសាសនា គួរផ្តល់ការបណ្តុះបណ្តាលវិក្រឹត្យការគរុកោសល្យដល់គ្រូបង្រៀនដែលនឹងជាប់កិច្ចសន្យា និងគ្រូសហគមន៍/ស្ម័គ្រចិត្ត មុនពេលពួកគេចាប់ផ្តើមបង្រៀន។

### ២. ផ្តល់ការបណ្តុះបណ្តាលអភិវឌ្ឍវិជ្ជាជីវៈជាបន្តបន្ទាប់ដល់គ្រូរដ្ឋ និងគ្រូជាប់កិច្ចសន្យា

ក្រសួងធម្មការ និងសាសនា គួរបន្តផ្តល់ការបណ្តុះបណ្តាលវិក្រឹត្យការជារៀងរាល់ឆ្នាំ មិនមែនសម្រាប់តែគ្រូរដ្ឋនោះទេ ប៉ុន្តែគឺសម្រាប់ទាំងគ្រូជាប់កិច្ចសន្យា និងគ្រូសហគមន៍/ស្ម័គ្រចិត្តផងដែរ។ ដូច្នេះ ក្រសួងធម្មការ និងសាសនា និងក្រសួង អយក គួរសហការគ្នារៀបចំវគ្គបណ្តុះបណ្តាលថ្នាក់ដឹកនាំ និងគណៈគ្រប់គ្រងសាលារៀនប្រចាំឆ្នាំសម្រាប់អ្នកគ្រប់គ្រងសាលាពុទ្ធិកសិក្សាទាំងអស់។

### ៣. ដាក់បញ្ចូលការបណ្តុះបណ្តាលថ្នាក់អាយុចម្រុះ និងថ្នាក់គួប ក្នុងការបណ្តុះបណ្តាលគរុកោលស្យ និងវិក្រឹត្យការ

ដោយសារតែសាលាពុទ្ធិកសិក្សាតែងមានសិស្សដែលមានអាយុ និងសមត្ថភាពចម្រុះក្នុងមួយថ្នាក់ៗ ក្រុមស្រាវជ្រាវសូមស្នើឲ្យក្រសួងធម្មការ និងសាសនា ដាក់បញ្ចូលវគ្គ ១ ឬ ២ ស្តីពីគរុកោសល្យថ្នាក់អាយុចម្រុះ និងថ្នាក់គួបក្នុងការបណ្តុះបណ្តាលគរុកោលស្យ និងវិក្រឹត្យការ។

### ៤. ការផ្តល់ថវិកាជាប្រព័ន្ធសម្រាប់ប្រតិបត្តិការសាលារៀន

ការបង្កើតហិរញ្ញប្បទានជាប្រព័ន្ធសម្រាប់ប្រតិបត្តិការសាលារៀនដោយរាជរដ្ឋាភិបាលកម្ពុជា នឹងធានានិរន្តរភាព និងភាពប្រសើរឡើងនៃប្រព័ន្ធអប់រំសាលាពុទ្ធិកសិក្សា។ ថ្វីបើរដ្ឋាភិបាលត្រូវផ្តល់ថវិកាយ៉ាងច្រើនក៏ដោយ ប៉ុន្តែវានឹងផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនលើសលុប ព្រោះពុទ្ធិកសិក្សាដើរតួនាទី យ៉ាងសំខាន់ក្នុងការផ្តល់ធនធានមនុស្សដ៏ល្អ ហើយវានឹងជួយអភិរក្សវប្បធម៌ និងប្រពៃណីរបស់កម្ពុជា។

# សាលារៀនបណ្តែតទឹក

## អនុសាសន៍រយៈពេលខ្លី

### ១. ផ្តល់ទូក និងសាហ៊ុយទិញប្រេងឥន្ធនៈដល់សាលារៀនបណ្តែតទឹក

សាលារៀនបណ្តែតទឹកត្រូវការទូកដើម្បីផ្តល់មធ្យោបាយធ្វើដំណើរដោយសុវត្ថិភាពដល់សិស្ស និងមូលនិធិបន្ថែមរយៈពេលវែងលើសាហ៊ុយប្រេងឥន្ធនៈ និងការទំនុកបម្រុងនានា។ សាលារៀនបណ្តែតទឹកត្រូវការទូកសម្រាប់

ដឹកជញ្ជូនសិស្ស និងគ្រូ និងផ្លាស់ទីតាំងរចនាសម្ព័ន្ធសាលារៀនតាមរដូវកាល។ ការផ្តល់ទូកជួយឲ្យសិស្សបានសិក្សា និងជួយដល់គ្រូរដ្ឋដែលច្រើនតែបំពេញការងារឯកឯងក្នុងការគ្រប់គ្រងសាលារៀនបណ្តែតទឹក។

## ២. ផ្គត់ផ្គង់អាវពោងដល់គ្រូ និងសិស្ស

ក្នុងការធានាសុវត្ថិភាពមូលដ្ឋានរបស់គ្រូ និងសិស្ស សាលារៀនបណ្តែតទឹកនឹងទទួលបានអត្ថប្រយោជន៍ពីការផ្តល់អាវពោងមួយចំនួន។ គ្រូ និងសិស្សជាច្រើនដែលយើងបានពិគ្រោះយោបល់ក្នុងពេលចុះដល់ទីតាំង មិនចេះហែលទឹកទេ។ មានន័យថា ពួកគេងាយនឹងលង់ទឹក។ អាវពោងនឹងជួយឲ្យកុមារបានចូលរៀន និងផ្តល់សន្តិសុខ និងកាត់បន្ថយហានិភ័យពាក់ព័ន្ធនឹងការធ្វើដំណើរទៅរៀន។

## ៣. ផ្តល់សម្ភារ/ឯកសារបង្រៀន និងរៀនថ្មីៗឲ្យបានគ្រប់គ្រាន់

សាលារៀនបណ្តែតទឹកនឹងទទួលបានប្រយោជន៍ពីសម្ភារ/ឯកសារបង្រៀន និងរៀនថ្មីៗដែលមានគម្របផ្លាស្ទិកធន់នឹង ទឹក និងការពុកផុយ។ ក្រៅពីសៀវភៅពុម្ព និងសៀវភៅលំហាត់ ចាំបាច់ត្រូវមានសៀវភៅគ្រូសម្រាប់ថ្នាក់គួបដែលបំពេញតម្រូវការសិក្សារបស់សិស្សគ្រប់វ័យ។

# អនុសាសន៍រយៈពេលវែង

## ១. កែសម្រួលរូបមន្តចំណាយប្រតិបត្តិការ

ក្រុមស្រាវជ្រាវសូមស្នើឲ្យក្រសួង អយក កែសម្រួលរូបមន្តថវិកាកម្មវិធីដែលកំណត់ពីចំណាយប្រតិបត្តិការសម្រាប់សាលារដ្ឋទាំងអស់ រួមទាំងសាលារៀនបណ្តែតទឹក។ ក្រៅពីថវិកាប្រតិបត្តិការសាលារៀន អយក បានផ្តល់ថវិកាបន្ថែមដល់សាលារៀនតូចៗ និងជួបការលំបាក។ ថវិកាប្រតិបត្តិការសាលារៀនបច្ចុប្បន្នមិនបានពិចារណាពីតម្រូវការតាមបរិបទ និងបញ្ហាប្រឈមរបស់សាលារៀនបណ្តែតទឹកឡើយ។

## ២. បង្កើនចំនួនអាហារូបករណ៍

សិស្សសាលារៀនបណ្តែតទឹកនឹងទទួលបានប្រយោជន៍ពីការបន្ថែមអាហារូបករណ៍ ដើម្បីឲ្យពួកគេអាចបន្តទៅមធ្យមសិក្សានៅដីគោក។ ការបង្កើនចំនួនអាហារូបករណ៍ដល់សិស្សសាលារៀនបណ្តែតទឹកនឹងជួយបង្កើនអត្រាឆ្លងភូមិសិក្សា ពីបឋមសិក្សា ទៅមធ្យមសិក្សា។

## ៣. សិក្សាពីលទ្ធភាពផ្តល់ការអប់រំពហុភាសា

សិស្សដែលរស់នៅក្នុងសហគមន៍បណ្តែតទឹកនឹងទទួលបានប្រយោជន៍ពីការអប់រំពហុភាសា។ ការមានគ្រូបង្រៀនដែលអាចជួយដល់សិស្សដែលមិននិយាយភាសាខ្មែរ ដើម្បីឲ្យពួកគេអាចបន្តទៅថ្នាក់ដំបូងនៅបឋមសិក្សា និងបន្តការសិក្សាក្រោយបញ្ចប់ថ្នាក់ទីមួយ នឹងជួយបង្កើនវត្តមាន និងពង្រីកលទ្ធភាពទទួលបានការអប់រំរបស់កុមារក្នុងសហគមន៍ទាំងនេះ។ ការអប់រំពហុភាសាក្នុងសាលារៀនដែលមានជាតិពន្ធុចម្រុះ នឹងជួយបង្កើនអត្រាអក្ខរភាព ក្នុងចំណោមសិស្សចាម និងសិស្សជាប់ខ្សែស្រឡាយវៀតណាម ហើយវានឹងជំរុញសមាហរណកម្មក្នុងសង្គមកម្ពុជា និងលើកកម្ពស់សង្គតភាពក្នុងសង្គម។

## ៤. បង្កើនការពិនិត្យតាមដាន និងជំនួយបច្ចេកទេសដល់សាលារៀន

សាលារៀនបណ្តែតទឹកនឹងទទួលបានប្រយោជន៍ពីការពិនិត្យតាមដាន និងជំនួយបច្ចេកទេសកាន់តែច្រើនពីការិយាល័យអយក។ ក្រុមស្រាវជ្រាវស្នើឲ្យមានការផ្តល់មូលនិធិបន្ថែមដល់ការិយាល័យ អយក ជាពិសេស សម្រាប់ការចុះអធិការកិច្ចញឹកញាប់ទៅកាន់សាលារៀនបណ្តែតឹក។ ក្រៅពីនេះ នាយកដ្ឋានសំណង់ របស់ក្រសួង អយក ដែលជាស្ថាប័នកំណត់ស្តង់ដារហេដ្ឋារចនាសម្ព័ន្ធសម្រាប់សាលារដ្ឋគួរផ្តល់ការណែនាំ និងពិនិត្យតាមដានស្តង់ដារ និងលក្ខខណ្ឌហេដ្ឋារចនាសម្ព័ន្ធសាលារៀនបណ្តែតទឹក។

### ៥. ហេដ្ឋារចនាសម្ព័ន្ធ និងធនធានទឹកស្អាត និងអនាម័យ

សាលារៀនបណ្តែតទឹកនឹងទទួលបានប្រយោជន៍ពីការពង្រីកហេដ្ឋារចនាសម្ព័ន្ធ និងធនធានទឹកស្អាត និងអនាម័យក្នុងសាលារៀន និងសហគមន៍បណ្តែតទឹកទាំងមូល។ ការអនុវត្តអនាម័យ និងធនធានដែលមានក្នុងសហគមន៍នេះត្រូវបានចម្លងតាមក្នុងសាលារៀនបណ្តែតទឹក។ ទាំងសាលារៀន និងសហគមន៍បណ្តែតទឹកសុទ្ធតែត្រូវការជម្រើសដែលកាន់តែមានអនាម័យពាក់ព័ន្ធនឹងការបន្ទោរបង់ ការលាងសម្អាត លទ្ធភាពទទួលបានទឹកស្អាត និងការបោះចោលសំរាម។

### ៦. ផ្តល់មុខវិជ្ជាបំណិនជីវិតមូលដ្ឋាន

ការសិក្សាបំណិនជីវិតមូលដ្ឋាននឹងជួយឲ្យសិស្សដែលរស់នៅក្នុងសហគមន៍បណ្តែតទឹក ត្រៀមខ្លួនប្រឈមនឹងតថភាពការងារថ្ងៃអនាគត  និងបំពាក់បំប៉នជំនាញដល់ពួកគេដើម្បីដោះស្រាយបញ្ហាប្រឈមនៃការប្រែប្រួលអាកាសធាតុ និងការឡើងកម្តៅផែនដី។ ក្រៅពីនេះ ការប្រឹក្សាអាជីពដែលជាផ្នែកមួយនៃបំណិនជីវិតមូលដ្ឋានសម្រាប់សិស្សថ្នាក់ទី ៥ និងទី ៦ អាចជាមធ្យោបាយដ៏មានប្រសិទ្ធភាពសម្រាប់ការបង្កើនអត្រាឆ្លងភូមិសិក្សា និងវត្តមានសិស្សនៅមធ្យមសិក្សា។

## សេចក្តីសន្និដ្ឋាន

ខណៈដែលការស្រាវជ្រាវនេះ កំណត់យកភាពងាយរងគ្រោះជាចំណុចស្នូលនៃការស្វែងយល់កាន់តែលម្អិតពីគុណភាព និងបរិយាបន្នក្នុងសាលារៀនទាំងបីប្រភេទនេះ មានវិធីជាច្រើនសម្រាប់ការស្រាវជ្រាវពីសាលារៀនឥស្លាម សាលាពុទ្ធិកសិក្សារៀន និងសាលារៀនបណ្តែតទឹក។ ក្រៅពីនេះ មានបញ្ហាអន្តរវិស័យជាច្រើនផ្សេងទៀតដែលមិនត្រូវបានលើកឡើងជាក់លាក់ក្នុងរបាយការណ៍នេះ ប៉ុន្តែគួបផ្សំនឹងបញ្ហាទាំងនេះ។ យ៉ាងណាមិញ រដ្ឋាភិបាល អង្គការយូនីសេហ្វ និងដៃគូអភិវឌ្ឍផ្សេងទៀតអាចប្រើប្រាស់របាយការណ៍នេះ និងអនុសាសន៍ពាក់ព័ន្ធដើម្បីបន្តពង្រីក និងពង្រឹងអន្តរាគមន៍អប់រំបច្ចុប្បន្នរបស់ខ្លួន។ ក្រុមស្រាវជ្រាវសូមស្នើឲ្យអ្នកតាក់តែងគោលនយោបាយ និងដៃគូអភិវឌ្ឍន៍ពិចារណាពីទស្សនៈវិស័យរបស់អ្នកពាក់ព័ន្ធចម្រុះនៅពេលរៀបចំអន្តរាគមន៍អប់រំ។ ធ្វើដូច្នេះទើបអាចដោះស្រាយតម្រូវការជាក់លាក់របស់សហគមន៍ជនជាតិភាគតិចដោយប្រសិទ្ធភាព។